# **ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
# **អគ្គសញ្ញាលាបថ្ងាសនៅអរិយក្សេត្រ**
# **ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៧**

អត្ថបទទី១៖ សរ ២២,២០-២៦
អត្ថបទទី២៖ ១ថស ១,៥-១០
ដំណឹងល្អ៖ មថ ២២,៣៤-៤០

បងប្អូនជាទីស្រឡាញ់!

អត្ថបទទីពីរថា "**ទោះបីបងប្អូនជួបប្រទះនូវទុក្ខលំបាក និងវេទនាធ្ងន់ធ្ងរយ៉ាងណាក៏ដោយ បងប្អូនបានទទួលព្រះបន្ទូលដោយមានអំណរមកពីព្រះវិញ្ញាណដ៏វិសុទ្ធ**"។ ថ្ងៃនេះដែលយើងសុំព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណដ៏វិសុទ្ធដល់បងប្អូន ជាឱកាសមួយដើម្បីនឹកឃើញថាយើងបានទទួលមរតកមួយយ៉ាងពិសេសគឺ "**ព្រះបន្ទូលរបស់ព្រះជាម្ចាស់**"។ យើងបានទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់តាមរបៀបមួយយ៉ាងប្លែក គឺនៅក្នុងអំណរសប្បាយននៃព្រះវិញ្ញាណដ៏វិសុទ្ធ។ នៅពេលនោះសន្តប៉ូលកំពុងនិយាយទៅគ្រីស្តបរិស័ទនៅថេសាឡូនិក ដែលបានប្រកាសដំណឹងល្អដល់បងប្អូនឯទៀតៗ។ លោកប៉ូលបន្តទៀតថា "**ហេតុនេះ បងប្អូនបានទៅជាគំរូដល់អ្នកជឿទាំងអស់នៅស្រុកម៉ាសេដូន នៅស្រុកអាគែន និងនៅកន្លែងផ្សេងៗទៀត**"។ ដូច្នេះព្រះបន្ទូលថ្ងៃនេះ ជាព្រះបន្ទូលសម្រាប់ប្អូនៗដែលកំពុងសុំទទួលអគ្គសញ្ញាលាបថ្ងាសមែនទែន។ យើងបានទទួលព្រះបន្ទូលនៅក្នុងអំណរសប្បាយ និងអំណរសប្បាយនេះ ព្រះបន្ទូលនេះណែនាំឲ្យយើងទៅជាគំរូសម្រាប់បងនប្អូនឯទៀតៗ ។ ធ្វើយ៉ាងម៉េច ដើម្បីទៅជាគំរូសម្រាប់បងប្អូនឯទៀតៗ? សម្រាប់យើងទាំងអស់ដែលជាគ្រីស្តបរិស័ទ យើងបានទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់តាំងពីយើងនៅកូនង៉ែត ឪពុកម្តាយឲ្យយើងទទួលអគ្គសញ្ញាជ្រមុជទឹកហើយ ពីជីដូនជីតារបស់យើងពីយូរហើយ។ ប៉ុន្តែពីមួយថ្ងៃទៅមួយថ្ងៃនៅពេលយើងចូលនៅក្នុងពិធីបុណ្យអភិបូជា ពេលយើងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាឱកាសមួយ ដើម្បីនឹកឃើញថ្ងៃនេះខ្ញុំមានអំណរសប្បាយ អំណរសប្បាយដោយសារខ្ញុំស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងព្រះបន្ទូលរបស់ព្រះជាម្ចាស់មានអត្ថន័យយ៉ាងពិសេសសម្រាប់ជីវិតរបស់ខ្ញុំ និងណែនាំឲ្យជីវិតរបស់ខ្ញុំរកឃើញផ្លូវដើម្បីទៅមុខ ណែនាំឲ្យជីវិតមានកម្លាំងដើម្បីធ្វើតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។

ដូច្នេះ ជីវិតរបស់យើងជាគ្រីស្តបរិស័ទ ជាជីវិតមួយយ៉ាងពិសេសដោយសារយើងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលដឹកនាំជីវិតរបស់យើង ដែលចិញ្ចឹមជីវិតរបស់យើង។ ដូច្នេះគំនិតនីមួយៗដែលយើងមានមិនមែនធម្មតាទេ គឺព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលបំភ្លឺយើង។ ជា

ពិសេសនៅអរិយ៍ក្សត្រ នៅក្នុងខែកក្កដាកន្លងមកព្រះនាងម៉ារីបានបង្ហាញខ្លួននៅព្រះសហគមន៍ព្រៃកប្រស់ ព្រះនាងម៉ារីទាំងពីរបានបង្ហាញខ្លួនដល់យាយម្នាក់ដែលកំពុងឈឺធ្ងន់ ដែលដើរមិនរួចស្ទើកប្រាំថ្ងៃ និងនៅក្នុងយល់សប្តិគាត់ឃើញបងស្រីម៉ារីអាឡៃ្ស នៅក្នុងក្រុមបងស្រីឧបការគុណ បងស្រីគាត់កំពុងនិយាយជាមួយព្រះនាងម៉ារីទាំងពីរ (គាត់ឃើញនៅក្នុងយល់សប្តិ) នៅពេលនោះព្រះនាងម៉ារីបាននិយាយទៅយាយហ្នឹង "សូមយកចិត្តទុកដាក់អធិដ្ឋាន មិនមែនអធិដ្ឋានផ្តាំតែ៥០ ប៉ុន្តែ១០០សូមអធិដ្ឋានច្រើនទៅៗ"។ ក្រោយមកបងស្រីអាឡៃ្ស បានយកប្រេងក្រឡា និងលាបឲ្យយាយដែលនៅព្រៃកប្រស់នោះ និងក្រោយមកគាត់ឈរឡើង។ ពេលគាត់ភ្ញាក់ពីដេក គាត់ក្តៅនៅក្នុងខ្លួននិងគាត់ដើរបានធម្មតា។

ដូច្នេះសម្រាប់បងប្អូនដែលជាគ្រីស្តបរិស័ទនៅទីនេះ យើងមិនមែននៅកន្លែងមួយធម្មតាទេ យើងនៅកន្លែងមួយដែលព្រះនាងម៉ារីការពារថែរក្សាយើងយ៉ាងខ្លាំង កន្លែងមួយដែលព្រះនាងម៉ារីបានណែនាំឲ្យយើងមានជីវិតមួយយ៉ាងពិសេស កន្លែងមួយដែលយើងត្រូវតែពោរពេញដោយអំណរសប្បាយ ដូចព្រះនាងម៉ារីដែលបានទទួលដំណឹងថាជាមាតរបស់ព្រះយេស៊ូ ព្រះនាងម៉ារីប្រញាប់ប្រញាល់ទៅជួបជាមួយយាយអេលីសាប៉ែត ដើម្បីចែករំលែកអំណរសប្បាយរបស់គាត់។

សម្រាប់យើងដែលជាគ្រីស្តបរិស័ទនៅទីនេះ យើងត្រូវការធ្វើយ៉ាងម៉េចដើម្បីប្រញាប់ប្រញាល់គ្រប់ពេលវេលា ដើម្បីចែករំលែកអំណរសប្បាយដែលយើងមាន ដោយសារយើងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ កន្លែងនេះមិនធម្មតាទេ! យើងមានកម្លាំងពីព្រះនាងម៉ារី ពីមួយថ្ងៃទៅមួយថ្ងៃ ហើយយើងដឹងរូបទីមួយនៅពេលយើងរកឃើញ អ្នកនេសាទត្រីអ៊ីស្លាមគាត់ផ្ញើទៅពុទ្ធបរិស័ទម្នាក់ដែលជាអ្នកទិញអេដចាយ ប៉ុន្តែគេចង់លក់ឲ្យយើង ចុងក្រោយបំផុតគេមិនលក់ឲ្យយើងដោយសារគេឃើញព្រះនាងម៉ារីនៅពេលយប់បង្ហាញខ្លួន។ ព្រះនាងម៉ារី មានអំណាចមួយយ៉ាងពិសេស ដែលណែនាំឲ្យយើងមានអំណរសប្បាយដូចព្រះនាងម៉ារីដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ។

ផ្លែនៃព្រះវិញ្ញាណដ៏វិសុទ្ធទីមួយគឺសេចក្តីស្រឡាញ់ ទីពីរអំណរ ទីបីសេចក្តីសុខសាន្ត។ អំណរសប្បាយនេះ មកពីព្រះវិញ្ញាណដ៏វិសទ្ធ ដូច្នេះយើងទទួលខុសត្រូវយ៉ាងធំណាស់ គឺធ្វើជាគំរូសម្រាប់បងប្អូនឯទៀតៗ។ ទីមួយ យើងមានអំណរសប្បាយទទួលព្រះបន្ទូល ទីពីរយើងធ្វើជាគំរូសម្រាប់បងប្អូនឯទៀតៗ។ នៅក្នុងសង្គមរបស់យើង ដែលមានគ្រីស្តបរិស័ទតិច យើងជាគំរូមួយយ៉ាងប្លែក ដោយសារមូលហេតុអ្វី យើងជឿលើព្រះយេស៊ូ? មូលហេតុអ្វី យើងផ្ញើជីវិតរបស់យើងទៅព្រះយេស៊ូ? មូលហេតុអ្វី រាល់ថ្ងៃអាទិត្យយើងចូលវិហារ? មូលហេតុអ្វី យើងសូត្រធម៌? រាល់អាទិត្យពេលយើងវាយជួងធំឲ្យគ្រីស្តបរិស័ទជួបជុំគ្នា ដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងទទួលជីវិតតាមរយៈព្រះកាយព្រះគ្រីស្ត។ នេះជាអំណរសប្បាយដែលយើងទទួល ប៉ុន្តែអំណរសប្បាយ

នេះណែនាំឲ្យយើងទទួលខុសត្រូវយ៉ាងពិសេសគឺ "**ទៅជាគំរូសម្រាប់បងប្អូនឯទៀតៗ**"។ យើងទទួលខុសត្រូវយ៉ាងខ្ពស់ ដើម្បីឲ្យបងប្អូនឯទៀតៗអាចមានឱកាសស្គាល់ជាមួយព្រះយេស៊ូ។ ប៉ុន្តែឥលូវនេះយើងត្រូវការសួរ យើងធ្វើយ៉ាងម៉េចដើម្បីធ្វើជាគំរូ? ឲ្យយើងស្តាប់ចម្លើយរបស់ព្រះយេស៊ូនៅក្នុងគម្ពីរដំណឹងល្អថ្ងៃនេះ ព្រះយេស៊ូបានឆ្លើយទៅគេដែលបានសួរដូច្នេះ "**លោកគ្រូអើយ! តើមានធម្មវិន័យណាដែលសំខាន់ជាងគេ?**" នៅក្នុងសាសនាយូដាគេមានធម្មវិន័យ ៦១៣វិន័យ ដូច្នេះពេលគេសួរព្រះយេស៊ូ គេសង្ឃឹមថាព្រះយេស៊ូឆ្លើយមិនបាន ដោយសារធ្វើយ៉ាងម៉េចដើម្បីជ្រើសរើសវិន័យមួយដ៏សំខាន់ នៅក្នុងចំណោម៦១៣វិន័យ។ ក្រោយមកគេសង្ឃឹម គេអាចចាប់ព្រះយេស៊ូដោយថា "មើល៍! យេស៊ូនេះមិនគោរពសាសនាយើងសោះ! ដោយសារយើងមាន៦១៣វិន័យគាត់រើសតែមួយយ៉ាងម៉េច?"។ ព្រះយេស៊ូមានព្រះបន្ទូលថា "**ត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នកឲ្យអស់ពីចិត្តគំនិត អស់ពីស្មារតី អស់ពីប្រាជ្ញា ហ្នឹងហើយជាវិន័យទីមួយដែលសំខាន់ជាងគេបំផុត**"។ ពិតមែននៅក្នុងសាសនាយូដា សំខាន់បំផុតគឺ "**អ៊ីស្រាអ៊ែលអើយ សូមស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងគោរពព្រះជាម្ចាស់**"។ សម្រាប់យើង ពេលយើងចង់ធ្វើជាគំរូ ឲ្យយើងគោរពព្រះជាម្ចាស់ស្រឡាញ់ព្រះជាម្ចាស់អស់ពីចិត្តគំនិត អស់ពីស្មារតី អស់ពីប្រាជ្ញា។ ប៉ុន្តែព្រះយេស៊ូឆ្លាត ព្រះយេស៊ូថែមទៀត មានវិន័យមួយទៀតដែលសំខាន់ស្មើគ្នាដែរគឺ "**នៅពេលយើងស្រឡាញ់ព្រះជាម្ចាស់អស់ពីដួងចិត្ត អស់ពីប្រាជ្ញា អស់ពីចិត្តគំនិត យើងត្រូវតែស្រឡាញ់បងប្អូនឯទៀតៗដែរ**"។ ដោយសារយើងមិនអាចស្រឡាញ់ព្រះជាម្ចាស់និងស្អប់អ្នកដទៃ ដោយសារព្រះជាម្ចាស់មានវត្តមាននៅក្នុងដួងចិត្តរបស់មនុស្សទាំងអស់។ ដូច្នេះពេលយើងជួបជាមួយមនុស្សម្នាក់ ហាក់បីដូចជាយើងជួបជាមួយព្រះជាម្ចាស់ យើងជួបជាមួយសត្រូវ យើងជួបជាមួយព្រះជាម្ចាស់ យើងជួបជាមួយមនុស្សដែលយើងមាននិស្ស័យ យើងជួបជាមួយព្រះជាម្ចាស់ យើងជួបជាមួយមនុស្សដែលយើងគ្មាននិស្ស័យ យើងជួបជាមួយព្រះជាម្ចាស់ដែរ យើងជួបជាមួយអ្នកក្រីក្រម្នាក់ដែលគ្មានទីពឹង យើងជួបជាមួយព្រះជាម្ចាស់ យើងជួបជាមួយអ្នកមានដែលទៅលេងកាស៊ីណូនៅណាហ្គា យើងជួបជាមួយព្រះជាម្ចាស់ដែរ។

យើងត្រូវការស្រឡាញ់ព្រះជាម្ចាស់ អស់ពីដួងចិត្ត អស់ពីស្មារតី អស់ពីចិត្តគំនិត ប៉ុន្តែយើងត្រូវតែស្រឡាញ់បងប្អូនឯទៀតៗដែរ។ **ព្រះជាម្ចាស់ណែនាំឲ្យយើងស្រឡាញ់** សេចក្តីស្រឡាញ់ដែលយើងទទួលពីព្រះជាម្ចាស់ ផ្សេងពីសេចក្តីស្រឡាញ់របស់មនុស្ស គឺមិនមែនសេចក្តីស្រឡាញ់តាមស្នេហា មិនមែនសេចក្តីស្រឡាញ់ដោយមាននិស្ស័យឬគ្មាននិស្ស័យ គឺសេចក្តីស្រឡាញ់ដែលចេញពីដួងចិត្តចេញពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺជាសេចក្តីស្រឡាញ់ដ៏ពេញលក្ខណៈ និងព្រះជាម្ចាស់ស្រឡាញ់មនុស្សទាំងអស់។ យើងជាគ្រីស្តបរិស័ទ ត្រូវធ្វើជាគំរូសម្រាប់បងប្អូនឯទៀតៗ។ ថ្ងៃនេះព្រះបន្ទូលរបស់ព្រះយេស៊ូ ណែនាំឲ្យយើងស្រឡាញ់ព្រះជាម្ចាស់អស់ពីដួងចិត្ត និង

ស្រឡាញ់បងប្អូនឯទៀតៗ។ ប៉ុន្តែថ្ងៃនេះយើងស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ ដែលព្រះយេស៊ូអត់ទាន់សោយទីវង្គត នៅពេលនោះព្រះយេស៊ូបានយកអត្ថបទវិន័យចេញពីធម្មវិន័យសម្ព័ន្ធមេត្រីចាស់។ ដូច្នេះព្រះយេស៊ូបាននិយាយដូចនេះ វិន័យទីពីរសំខាន់ដូចគ្នាដែរគឺ "**ត្រូវស្រឡាញ់បងប្អូនឯទៀតៗឲ្យបានដូចស្រឡាញ់ខ្លួនឯង**"។ ប៉ុន្តែ យើងត្រូវការនឹកឃើញធម្មវិន័យចុងក្រោយរបស់ព្រះយេស៊ូ មុនព្រះយេស៊ូសោយទីវង្គត ព្រះយេស៊ូបានប្រមូលក្រុមគ្រីស្តទូត ព្រះយេស៊ូបានលាងជើងឲ្យក្រុមគ្រីស្តទូត ក្រោយមកព្រះយេស៊ូមានព្រះបន្ទូលអំពីធម្មវិន័យចុងក្រោយ "**សូមស្រឡាញ់គ្នាទៅវិញទៅមកដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ**"។ មានន័យថា នៅពេលយើងស្រឡាញ់បងប្អូនឯទៀតៗ យើងយកព្រះយេស៊ូជាគំរូ មិនមែនយកយើងផ្ទាល់ខ្លួនជាគំរូ យកព្រះយេស៊ូជាគំរូដើម្បីស្រឡាញ់បងប្អូនឯទៀតៗ។ មានសន្តមួយដែលពូកែស្រឡាញ់ គឺសន្តវ៉ាំងសង់ដឺប៉ូល អស់មួយជីវិតរបស់គាត់ គឺគាត់លះបង់ចោលដើម្បីស្រឡាញ់អ្នកក្រីក្រ ដើម្បីបម្រើអ្នកជំងឺអស់មួយជីវិតរបស់គាត់។ មានថ្ងៃមួយមានមីងម្នាក់សួរគាត់ "លោកឪពុកខ្ញុំធ្វើយ៉ាងម៉េច? ខ្ញុំអធិដ្ឋាននៅមុខព្រះកាយពេញមួយម៉ោង និងនៅម៉ោងហ្នឹងមានអ្នកក្រីក្រម្នាក់មករំខានខ្ញុំដើម្បីសុំឲ្យខ្ញុំជួយគាត់។ ដូច្នេះ ខ្ញុំធ្វើយ៉ាងម៉េច? ខ្ញុំកំពុងអធិដ្ឋានជាមួយព្រះយេស៊ូ បង្ហាញសេចក្តីស្រឡាញ់ដែលខ្ញុំមានចំពោះព្រះជាម្ចាស់ ខ្ញុំធ្វើដូចម្តេចដើម្បីជួបអ្នកក្រីក្រនេះដែលកំពុងរំខានខ្ញុំ?"។ គាត់ឆ្លើយថា "អត់អីទេ នៅពេលកំពុងអធិដ្ឋាននៅមុខព្រះកាយព្រះគ្រីស្ត គឺការគោរពព្រះជាម្ចាស់នៅក្នុងសេចក្តីស្រឡាញ់ដែលយើងមានអស់ពីដួងចិត្ត អស់ពីប្រាជ្ញា អស់ពីចិត្តគំនិត។ ប៉ុន្តែប្រសិនបើចោលព្រះកាយព្រះគ្រីស្ត ដើម្បីជួបជាមួយអ្នកក្រីក្រហ្នឹងក៏ដូចគ្នាដែរ ដោយសារព្រះជាម្ចាស់នៅក្នុងអ្នកក្រីក្រនោះ"។ ដូច្នេះកុំឲ្យយើងភ្លេចជីវិតរបស់យើងគឺអធិដ្ឋាននៅមុខព្រះកាយ ស្តាប់ព្រះបន្ទូល ចូលអភិបូជា ប៉ុន្តែជីវិតរបស់យើង គឺស្រឡាញ់បងប្អូនឯទៀតៗជាក់ស្តែងមិនមែនលេងៗ។ ព្រះយេស៊ូមិនឲ្យយើងស្រឡាញ់លេងៗទេ ឲ្យយើងស្រឡាញ់ពិតអស់ពីដួងចិត្ត ទាំងព្រះជាម្ចាស់ ទាំងបងប្អូនឯទៀតៗ។

ដូច្នេះថ្ងៃនេះយើងអរព្រះគុណព្រះជាម្ចាស់ ដែលណែនាំឲ្យយើងធ្វើជាគ្រីស្តបរិស័ទដ៏ពេញលក្ខណៈ ពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ពោរពេញដោយអំណរសប្បាយ ដើម្បីបន្តការប្រកាសដំណឹងល្អតាមរបៀបព្រះយេស៊ូ ដោយសម្លឹងមើលព្រះនាងម៉ារីជានិច្ច។ ដោយសារព្រះនាងម៉ារីណែនាំឲ្យយើងធ្វើតាមព្រះយេស៊ូរហូត។ ប្រសិនបើយើងអត់ចេះស្រឡាញ់គេ ប្រសិនបើយើងមិនរវីរវល់នឹងព្រះសហគមន៍ ប្រសិនបើយើងភ្លេចចូលព្រះវិហារ ថ្ងៃណាមួយព្រះនាងម៉ារីបង្ហាញខ្លួននៅក្នុងយល់សប្តិរបស់បងប្អូននឹងសួរថា "មួយថ្ងៃទៅមួយថ្ងៃធ្វើអី មិនចេះស្រឡាញ់កូនខ្ញុំសោះ?"។ ផ្ទុយទៅវិញ ឲ្យយើងត្រៀមខ្លួនដើម្បីស្តាប់ព្រះនាងម៉ារីដែលបង្ហាញខ្លួនឲ្យយើងនឹងមានបន្ទូលដល់យើងថា "កូនអើយ កុំភ្លេច! សូមស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូជានិច្ច ដោយស្រឡាញ់និងបម្រើដោយបម្រើនិងស្រឡាញ់"។ អាម៉ែន៕